

# ពេលដែលត្រូវយំ

ដោយ សឹង-សម្រេច

ថ្ងៃទី២២ ធ្នូ ២០០៩

១- ជាតិមនុស្សក្នុងលោក ចង់តែសើច ការកុំឲ្យខឹច អាយុខ្លី
ណាត់គ្នាស៊ីផឹក លេងសំដី ស្តាប់ល្ខោន អាយ៉ៃ ឆាកកំប្លែង ។

២- បើយំ គេឃើញ គឺមនុស្សខ្សោយ ត្រូវយំក៏ដោយ យំម្នាក់ឯង
ក្នុងទីប្រជុំ ត្រូវខែងរ៉ែង ស្រវឹង គេសែង ក៏កុំយំ ។

៣- ប៉ុន្តែមានខ្មែរមួយចំនួន យំមិនដឹងខ្លួនរាល់ប្រជុំ
ភ្លេងជាតិ រោលចិត្ត អួលរងំ ក្តុកក្តួលទុក្ខធំ ទ្រាំមិនបាន ។

៤- ខ្មែរក្រោម ជួបគ្នា យំរាល់ឆ្នាំ យំជាប្រចាំ មិនដែលខាន
ទឹកភ្នែកហៀរហូរ ហួសពីស្មាន យំស្រយុតប្រាណ ណែនឱរា ។

៥- បើកឡានច្រើនម៉ោង ហោះឆ្លងរដ្ឋ អាមេរិក រហូតអូស្ត្រាលីយ៉ា
អឺរ៉ុប អាស៊ី កាណាដា ជួបគ្នាកាលណា នាំគ្នាយំ ។

៦- យំទាំងអ្នកថ្លែង ទាំងអ្នកស្តាប់ យំចិត្តឈឺចាប់ ទុក្ខប៉ុនភ្នំ
ទង់ជាតិ សាសនា ភ្លេងរងំ ខ្មែរក្រោមទុក្ខធំ ត្រូវគេជាន់ ។

៧- រាល់ឆ្នាំ ប្តូរទីយំគ្រប់គ្នា តាមរដ្ឋនានា សហព័ន្ធ
តំណក់ទឹកភ្នែក តជំនាន់ យំហើយរួសរាន់ ដោះបញ្ហា ។

៨- បងប្អូនជាតិខ្មែរ រួមលោហិត បើមិនអាណិត សូមមេត្តា!
យកទឹកភ្នែកខ្មែរ ពិចារណា កុំភ្លេចជួយគ្នា រកសេរី ។

៩- ទាំងខ្មែរដែលជាប់មាត់ប្រឹងសើច សើចភ្លេចពេលខឹច ជិតអស់ដី
មើលទុក្ខខ្មែរក្រោម ទាំងប្រុស-ស្រី ប្រយ័ត្នគិតខ្លី យំឆ្លងគ្នា ។

១០- ជាតិយើងតែមួយ មហានគរ ម្តេចប្រែវិកវរ បែកឃ្លាតឃ្លា?
មានយំ មានសើច រឿងកម្ពុជា ថ្ងៃណាសាមគ្គា ឯកភាពបាន?! ។៚